**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ឯកឧត្តម ឧត្តមសេនីយ៍ឯក រ៉ាត់ ដារ៉ាវុធ រដ្ឋលេខាធិការក្រសួងការពារជាតិ ធ្វើបទបង្ហាញជូនអនុព័ន្ធយោធាបរទេស ប្រចាំព្រះរាជាណាចក្រកម្ពុជា (MACPP) អំពីស្ថានភាពតាមបណ្តោយព្រំដែនកម្ពុជា–ថៃ

នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៦ វេលាម៉ោង ៩:០០ព្រឹក **ឯកឧត្តម ឧត្តមសេនីយ៍ឯក រ៉ាត់ ដារ៉ាវុធ រដ្ឋលេខាធិការក្រសួងការពារជាតិ** បានដឹកនាំធ្វើបទបង្ហាញជូនក្រុមអនុព័ន្ធយោធាបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា (MACPP) ដែលមានចំនួន ២២រូប តំណាងមកពី ១៨ប្រទេស ស្តីពីបច្ចុប្បន្នភាព និងស្ថានការណ៍ចុងក្រោយតាមបណ្តោយព្រំដែនកម្ពុជា–ថៃ នៅទីស្តីការក្រសួងការពារជាតិ។

ក្នុងកិច្ចប្រជុំនេះ **ឯកឧត្តម រដ្ឋលេខាធិការ** បានថ្លែងអំណរគុណចំពោះក្រុមអនុព័ន្ធយោធាបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា (MACPP) ដែលបានចូលរួមក្នុងបទបង្ហាញនាថ្ងៃនេះ ក៏ដូចជាការចូលរួមចុះពិនិត្យដោយផ្ទាល់នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃនាពេលកន្លងមក។ **ឯកឧត្តម រដ្ឋលេខាធិការ** បានធ្វើបទបង្ហាញអំពីសារបាននៃការវិវត្តន៍ស្ថានការណ៍មុនពេលប៉ះទង្គិចប្រដាប់អាវុធតាមបណ្តោយព្រំដែន រហូតឈានទៅដល់ បទឈប់បាញ់កាលពីខែធ្នូ ឆ្នាំ២០២៥ និងការវិវត្តន៍នៃបរិបទសន្តិសុខនៅតាមតំបន់ព្រំដែននាពេលបច្ចុប្បន្ន ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជានាពេលកន្លងមកក្នុងការដោះស្រាយបញ្ហាព្រំដែនកម្ពុជា-ថៃ។

ជាមួយគ្នានេះ ក្រុមការងារជំនាញមកពីបណ្តាអង្គភាពពាក់ព័ន្ធក៏បានចូលរួមធ្វើបទបង្ហាញអំពីការវិវត្តន៍ការងាររបស់ខ្លួនផងដែរ។ ក្នុងនោះ តំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន បានធ្វើបទបង្ហាញអំពីការវិវត្តន៍ និងសមិទ្ធផលការងារដែលបានអនុវត្តកន្លងមក ជាពិសេសការងារបោះបង្គោលបណ្តោះអាសន្ននៅកំណាត់ខ្សែព្រំដែននៅចន្លោះបង្គោលព្រំដែនលេខ៥២ ដល់លេខ៥៩ និងចន្លោះបង្គោលព្រំដែនលេខ៤២ ដល់ លេខ៤៧ នៅអំឡុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២៥ មុនការប៉ះទង្គិចគ្នាតាមបណ្តោយព្រំដែនលើកទី២ ព្រមទាំងរំលេចអំពីកិច្ចខិតខំប្រឹងប្រែងរបស់ភាគីកម្ពុជា ក្នុងការជំរុញឱ្យមានកិច្ចប្រជុំគណៈកម្មការព្រំដែនចម្រុះ (JBC) និងស្នើឱ្យភាគីថៃចាត់បញ្ជូនក្រុមវាស់វែងចម្រុះ (JSTs) ដើម្បីបន្តចុះអនុវត្តការងារនៅលើដីជាក់ស្តែង ដែលជាយន្តការទ្វេភាគីដែលមានស្រាប់រវាងកម្ពុជា–ថៃ សំដៅស្វែងរកដំណោះស្រាយជាអចិន្ត្រៃយ៍ចំពោះបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ។

បន្ទាប់មក ក្រុមអ្នកសម្របសម្រួល (CLG) នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើបទបង្ហាញអំពីប្រវត្តិនៃការបង្កើត តួនាទី និងការរួមចំណែករបស់ CLG ក្នុងការពង្រឹងការសម្របសម្រួលជាមួយយន្តការក្រុមអ្នកសង្កេត-

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh

ការណ៍អាស៊ាន (AOT) ឱ្យកាន់តែមានប្រសិទ្ធភាព ស្របតាមស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាព ថ្ងៃ២៦ ខែតុលា ឆ្នាំ ២០២៥ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី និងយន្តការដែលពាក់ព័ន្ធ។ បទបង្ហាញបានរំលេចនូវសមិទ្ធផល នៃកិច្ចខិតខំប្រឹងប្រែងរបស់ ក្រុមCLG ក្នុងការសម្របសម្រួលជូន AOT ចុះសង្កេតការណ៍ ផ្ទៀងផ្ទាត់ និងរាយការណ៍អំពីស្ថានភាពជាក់ស្តែងតាមបណ្តោយព្រំដែនកម្ពុជា–ថៃ ស្របតាមស្មារតីនៃសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា–ថៃ (GBC) ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ ទន្ទឹមគ្នានេះ ក្រុម CLG បានសម្តែងនូវការកោតសរសើរ និងអំណរគុណចំពោះប្រទេសម៉ាឡេស៊ី ដែលបានដើរតួនាទីដឹកនាំ និងរួមចំណែកយ៉ាងសំខាន់ក្នុងដំណាក់កាលដំបូងនៃបេសកកម្ម AOT នៅកម្ពុជា រហូតឈានដល់ប្រធានប្តូរវេនហ្វីលីពីន ដែលបានបន្តបំពេញតួនាទីយ៉ាងសកម្ម និងប្រកបដោយការទទួលខុសត្រូវ ក្នុងការគាំទ្រដល់ការអនុវត្តយន្តការរបស់អាស៊ាន និងការរួមចំណែកដល់សន្តិភាព ស្ថិរភាព និងសាមគ្គីភាពក្នុងតំបន់។

កិច្ចប្រជុំនេះបានផ្តល់នូវវេទិកាដ៏សំខាន់មួយសម្រាប់ភាគីកម្ពុជា ក្នុងការផ្តល់ព័ត៌មានដោយផ្ទាល់ ផ្លាស់ប្តូរយោបល់ និងឆ្លើយតបទៅនឹងសំណួររបស់ក្រុមអនុព័ន្ធយោធាបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា (MACPP) ជាពិសេសលើយន្តការនៃវាស់វែងព្រំដែនរវាងប្រទេសទាំងពីរ ព្រមទាំងរួមចំណែកលើកកម្ពស់តម្លាភាព ការយោគយល់គ្នា និងការយល់ដឹងប្រកបដោយភាពច្បាស់លាស់ និងត្រឹមត្រូវ អំពីបច្ចុប្បន្នភាព និងការវិវត្តន៍នៃស្ថានការណ៍តាមបណ្តោយព្រំដែនកម្ពុជា–ថៃ។

**ឯកឧត្តម រដ្ឋលេខាធិការ** បានសង្កត់ធ្ងន់ថា បើទោះបីជាភាគីទាំងពីរបានព្រមព្រៀងគ្នាលើបទឈប់បាញ់ និងមានយន្តការសម្រាប់អនុវត្តដើម្បីដោះស្រាយបញ្ហាព្រំដែនរវាងប្រទេសទាំងពីរយ៉ាងណាក្តី ក៏ស្ថានការណ៍ជាក់ស្តែងនៅតាមបណ្តោយព្រំដែននៅតែប្រឈមនឹងផលប៉ះពាល់អវិជ្ជមានមួយចំនួន ដូចជា ការចល័តកងទ័ព ការរាយបន្លាលួស ការដាក់កុងតឺន័រ និងការសាងសង់សំណង់រឹង ដែលបាននិងកំពុងផ្លាស់ប្តូរស្ថានភាពជាក់ស្តែងនៅលើដី និងរាំងដល់ការវិលត្រឡប់របស់ប្រជាជនស្លូតត្រង់កម្ពុជាទៅកាន់លំនៅឋានរបស់ខ្លួនវិញ។ បញ្ហាទាំងនេះនៅតែជាបញ្ហាប្រឈម និងទាមទារឱ្យមានការដោះស្រាយជាបន្ទាន់។

កិច្ចប្រជុំនេះក៏បានបង្ហាញពីការបន្តប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការរក្សាសន្តិភាព សន្តិសុខ និងស្ថិរភាពតាមបណ្តោយព្រំដែន ព្រមទាំងជំរុញការសន្ទនា ការទំនាក់ទំនង និងការសម្របសម្រួលប្រកបដោយស្ថាបនា តាមរយៈយន្តការដែលមានស្រាប់ និងបណ្តាញទំនាក់ទំនងសមស្រប។

**ឯកឧត្តម រដ្ឋលេខាធិការ** បានបញ្ចប់ដោយបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ ស្មោះត្រង់ និងសុចរិតរបស់កម្ពុជា ក្នុងការគោរព និងអនុវត្តយ៉ាងពេញលេញ និងខ្ជាប់ខ្ជួនបំផុត នូវសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា–ថៃ (GBC) ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ សេចក្តីថ្លែង-ការណ៍រួមស្តីពីកិច្ចព្រមព្រៀងសន្តិភាពរវាងកម្ពុជា និងថៃ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ និងកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងទៀត ដើម្បីឆ្ពោះទៅរកការធ្វើឱ្យស្ថានការណ៍ប្រសើរឡើងវិញក្នុងពេលឆាប់ៗ និងការវិលត្រឡប់ទៅរកភាពប្រក្រតី សន្តិភាព និងស្ថិរភាពយូរអង្វែង។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៦

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh